**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៨ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងនិងការកំណត់បៀវត្សប្រចាំខែនិងការឧបត្ថម្ភផ្សេងៗ សម្រាប់មន្ត្រីរាជការនិងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០២/០០១ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីក្រមការការបរទេស

- បានឃើញអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យរបស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- បានឃើញអនុក្រឹត្យលេខ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

អនុក្រឹត្យនេះមានគោលបំណងរៀបចំការគ្រប់គ្រងនិងការកំណត់បៀវត្សប្រចាំខែនិងការឧបត្ថម្ភផ្សេងៗសម្រាប់មន្ត្រីរាជការនិងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស។

**មាត្រា២ ..**

អនុក្រឹត្យនេះមានគោលដៅកំណត់៖

- បៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន និងការឧបត្ថម្ភផ្សេងៗ
- ការគ្រប់គ្រងមន្ត្រីនិងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស
- វិធាននៃការបើកផ្តល់បៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន និងការឧបត្ថម្ភផ្សេងៗ។

**មាត្រា៣ ..**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ មន្ត្រីនគរបាលជាតិកម្ពុជា និងបុគ្គលិកដែលត្រូវបានចាត់តាំងឱ្យទៅបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស។

## ជំពូកទី២
## ការកំណត់បៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន និងការឧបត្ថម្ភផ្សេងៗ

**មាត្រា៤ ..**

បៀវត្សប្រចាំខែនិងប្រាក់ឧបត្ថម្ភឈ្នួលផ្ទះរបស់មន្ត្រីរាជការស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ មន្ត្រីនគរបាលជាតិកម្ពុជា និងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេសត្រូវបានកំណត់ទៅតាមប្រភេទចំណាត់ថ្នាក់ប្រទេសដូចខាងក្រោម៖

| លរ | ប្រភេទប្រទេស "ក" | ប្រភេទប្រទេស "ខ" | ប្រភេទប្រទេស "គ" |
|---|---|---|---|
| ១ | ប្រទេសអូស្ត្រាលីនិងនូវែលសេឡង់<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅកង់បេរ៉ា | ប្រទេសព្រុយណេដារូសាឡាម<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅបានដាសេរីបេហ្គាវ៉ាន់ | សាធារណរដ្ឋប៊ុលហ្គារី<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅសូហ្វីយ៉ា |

| ល.រ | ប្រភេទប្រទេស "ក" | ប្រភេទប្រទេស "ខ" | ប្រភេទប្រទេស "គ" |
|---|---|---|---|
| ២ | ប្រទេសបែលហ្ស៊ិក<br>-ស្ថានឯកអគ្គរាជទូតប្រចាំនៅព្រុចសែល<br>-ស្ថានបេសកកម្មអចិន្ត្រៃយ៍អមសហគមន៍អឺរ៉ុប-ព្រុចសែល | សាធារណរដ្ឋគុយបា<br>-ស្ថានឯកអគ្គរាជទូតប្រចាំនៅឡាហាវ៉ាន | សាធារណរដ្ឋឆែក<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅប្រាក |
| ៣ | ប្រទេសកាណាដា<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅអូតាវ៉ា | | សាធារណរដ្ឋហុងគ្រី<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅប៊ុយដាប៉ែស |
| ៤ | សាធារណរដ្ឋប្រជាមានិតចិន<br>-ស្ថានឯកអគ្គរាជទូតប្រចាំនៅប៉េកាំង | - ស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុងហុងកុងនិងម៉ាកាវ<br>- ស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុងសៀងហៃ<br>- ស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុងឆុងឈីង<br>- ស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុងគុនមិញ<br>- ស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុងណាននីង<br>- ស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុងស៊ីអាន<br>- ស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុងក្វាងចូវ | |
| ៥ | សាធារណរដ្ឋបារាំង<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅប៉ារីស<br>- ស្ថានគណៈប្រតិភូអចិន្ត្រៃយ៍ប្រចាំនៅអង្គការយូណេស្កូ | សាធារណរដ្ឋឥណ្ឌា<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅញូដេលី | |
| ៦ | សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់<br>-ស្ថានឯកអគ្គរាជទូតប្រចាំនៅប៊ែរឡាំង | សាធារណរដ្ឋឥណ្ឌូណេស៊ី<br>-ស្ថានឯកអគ្គរាជទូតប្រចាំនៅហ្សាការតា<br>-ស្ថានតំណាងអចិន្ត្រៃយ៍អមលេខាធិការដ្ឋានអាស៊ាន | |
| ៧ | ប្រទេសជប៉ុន<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅតូក្យូ | សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ<br>-ស្ថានឯកអគ្គរាជទូតប្រចាំនៅព្យុងយ៉ាង | |
| ៨ | សាធារណរដ្ឋកូរ៉េខាងត្បូង<br>-ស្ថានឯកអគ្គរាជទូតប្រចាំនៅសេអ៊ូល | សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅវៀងចន្ទន៍<br>- ស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុងប៉ាក់សេ | |

| ល.រ | ប្រភេទប្រទេស "ក" | ប្រភេទប្រទេស "ខ" | ប្រភេទប្រទេស "គ" |
|---|---|---|---|
| ៩ | រដ្ឋគុវ៉ែត<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅគុវ៉ែត | ប្រទេសម៉ាឡេស៊ី<br>-ស្ថានឯកអគ្គរាជទូតប្រចាំនៅគួឡាឡាំពួ | |
| ១០ | សហព័ន្ធរុស្ស៊ី<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅមូស្គូ | ប្រទេសមីយ៉ាន់ម៉ា<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅ យ៉ាំងហ្គូន | |
| ១១ | ប្រទេសស្វ៊ីស<br>- ស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំ អង្គការសហប្រជាជាតិ អង្គការ ពាណិជ្ជកម្មពិភពលោក និងអង្គការ អន្តរជាតិនានានៅហ្សឺណែវ | សាធារណរដ្ឋហ្វីលីពីន<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅម៉ានីល | |
| ១២ | ចក្រភពអង់គ្លេស<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅ ទីក្រុងឡុងដ៍ | ប្រទេសសេណេហ្គាល់<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅដាកា | |
| ១៣ | សហរដ្ឋអាមេរិក<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅ វ៉ាស៊ីនតោន<br>- ស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំ អង្គការសហប្រជាជាតិនៅញូវយ៉ក | សាធារណរដ្ឋសិង្ហបុរី<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅសិង្ហបុរី | |
| ១៤ | សាធារណរដ្ឋអារ៉ាប់អេហ្ស៊ីប<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅទីក្រុងគែរ | ព្រះរាជាណាចក្រថៃ<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅបាងកក<br>- ស្ថានអគ្គកុងស៊ុលប្រចាំនៅខេត្ត សាកែវ | |
| ១៥ | | សាធារណរដ្ឋសង្គមនិយមវៀតណាម<br>- ស្ថានឯកអគ្គរាជទូតប្រចាំនៅ ហាណូយ<br>- ស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុង ហូជីមិញ | |

**មាត្រា៥ ..**

បៀវត្សប្រចាំខែរបស់មន្ត្រីនិងបុគ្គលិកដែលបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស ត្រូវបានកំណត់ដូចខាងក្រោម៖

ឯកតា៖ គិតជាដុល្លារអាមេរិក

| ល.រ | មុខតំណែង | ប្រភេទប្រទេស | | |
|---|---|---|---|---|
| | | ក | ខ | គ |
| ១ | - ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព | ៣ ២០០ | ២ ៦០០ | ២ ៥០០ |

| ល.រ | មុខតំណែង | ប្រភេទប្រទេស | | |
|---|---|---|---|---|
| | | ក | ខ | គ |
| ២ | - អនុប្រធានស្ថានតំណាងអចិន្ត្រៃយ៍(ឋានៈជាអគ្គរាជទូត) | ៣ ០០០ | | |
| ៣ | - ភារធារីពេញសមត្ថភាព<br>- អគ្គទីប្រឹក្សាស្ថានទូតឬស្ថានតំណាងអចិន្ត្រៃយ៍ | ២ ៧០០ | ២ ២០០ | ២ ១០០ |
| ៤ | - ទីប្រឹក្សាស្ថានទូតឬស្ថានតំណាងអចិន្ត្រៃយ៍<br>- ទីប្រឹក្សាយោធា<br>- ទីប្រឹក្សានគរបាលជាតិ<br>- ទីប្រឹក្សាបច្ចេកទេស(សេដ្ឋកិច្ច ពាណិជ្ជកម្ម អប់រំ វប្បធម៌ និងការងារពលករ)<br>- អគ្គកុងស៊ុល | ២ ៤០០ | ២ ០០០ | ១ ៩០០ |
| ៥ | - លេខាធិការទី១ ស្ថានទូតឬស្ថានតំណាងអចិន្ត្រៃយ៍<br>- អនុព័ន្ធយោធា<br>- អនុព័ន្ធនគរបាលជាតិ<br>- អនុព័ន្ធជំនាញបច្ចេកទេស(សេដ្ឋកិច្ច ពាណិជ្ជកម្ម អប់រំ វប្បធម៌ និងការងារពលករ) | ២ ៣០០ | ១ ៨០០ | ១ ៧០០ |
| ៦ | - លេខាធិការទី២ ស្ថានទូតឬស្ថានតំណាងអចិន្ត្រៃយ៍<br>- កុងស៊ុល<br>- អនុព័ន្ធយោធារង | ២ ១០០ | ១ ៦០០ | ១ ៥០០ |
| ៧ | - លេខាធិការទី៣ ស្ថានទូតឬស្ថានតំណាងអចិន្ត្រៃយ៍<br>- អនុកុងស៊ុល | ២ ០០០ | ១ ៥០០ | ១ ៤០០ |
| ៨ | - អនុព័ន្ធស្ថានទូតឬស្ថានតំណាងអចិន្ត្រៃយ៍<br>- អនុព័ន្ធទទួលបន្ទុកគណនេយ្យ<br>- ភ្នាក់ងារកុងស៊ុលទទួលបន្ទុកគណនេយ្យ | ១ ៩០០ | ១ ៤០០ | ១ ៣០០ |
| ៩ | - គណនេយ្យករ<br>- បុគ្គលិករដ្ឋបាលនិងបច្ចេកទេស (ជំនួយការរដ្ឋបាល យោធា ជំនួយការទីប្រឹក្សាការងារ) | ១ ៦០០ | ១ ៣០០ | ១ ២០០ |
| ១០ | - បុគ្គលិកសេវា(អ្នកបើកបរនិងអ្នកដាំស្ល) | ១ ៤០០ | ១ ១០០ | ១ ០០០ |

**មាត្រា៦ .-**

បុគ្គលិកសេវាពុំទទួលបានប្រាក់ឧបត្ថម្ភឈ្នួលផ្ទះឡើយ។ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ត្រូវបានផ្ដល់ជូនមន្ត្រី និងបុគ្គលិករដ្ឋបាលនិងបច្ចេកទេសដែលមិនមានអគារស្នាក់នៅផ្អែកលើការកំណត់ដូចខាងក្រោម៖

ឯកតា៖ គិតជាដុល្លារអាម៉េរិក

| ល.រ | មុខតំណែង | ប្រភេទប្រទេស | | |
|---|---|---|---|---|
| | | ក | ខ | គ |
| ១ | ចាប់ពីថ្នាក់អនុប្រធានស្ថានតំណាងអចិន្ត្រៃយ៍ដល់ថ្នាក់លេខាធិការទី១និងថ្នាក់ប្រហាក់ប្រហែល(យោងតាមតារាងដែលមានកំណត់ក្នុងមាត្រា៥ខាងលើ) | ១ ៥០០ | ១ ២០០ | ១ ១០០ |

| ល.រ | មុខតំណែង | ប្រភេទប្រទេស | | |
|---|---|---|---|---|
| | | ក | ខ | គ |
| ២ | ចាប់ពីថ្នាក់លេខាធិការទី២ដល់ថ្នាក់អនុព័ន្ធស្ថានទូតនិងថ្នាក់ប្រហាក់ប្រហែល(យោងតាមតារាងដែលមានកំណត់ក្នុងមាត្រា៥ខាងលើ) | ១ ៤០០ | ១ ១០០ | ១ ០០០ |
| ៣ | បុគ្គលិករដ្ឋបាលនិងបច្ចេកទេស និងថ្នាក់ប្រហាក់ប្រហែល (យោងតាមតារាងដែលមានកំណត់ក្នុងមាត្រា៥ខាងលើ) | ១ ៣០០ | ១ ០០០ | ៩០០ |

**មាត្រា៧ ..**

ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូនប្រចាំខែរបស់មន្ត្រី និង បុគ្គលិកដែលបំពេញមុខងារដូចមានក្នុងតារាងនៃមាត្រា៥ខាងលើ លើកលែងតែបុគ្គលិកសេវា ត្រូវបានកំណត់ដូចតទៅ៖

- ប្រពន្ធឬប្តីត្រូវទទួលប្រាក់ឧបត្ថម្ភសហព័ទ្ធប្រចាំខែចំនួន២០០(ពីររយ)ដុល្លារអាម៉េរិកសម្រាប់សហព័ទ្ធដែលទៅតាមនិងត្រូវមានសំបុត្រអាពាហ៍ពិពាហ៍បញ្ជាក់
- កូនក្នុងបន្ទុកដែលមានអាយុក្រោម១៨ឆ្នាំ ត្រូវទទួលប្រាក់ឧបត្ថម្ភប្រចាំខែចំនួន១០០(មួយរយ)ដុល្លារអាម៉េរិកសម្រាប់កូនដែលទៅតាមឪពុកឬម្តាយនិងត្រូវមានសំបុត្រកំណើតបញ្ជាក់។

**មាត្រា៨ ..**

ឯកអគ្គរាជទូត ត្រូវបានអនុញ្ញាតឱ្យយកប្រពន្ធឬប្តី ព្រមទាំងកូនក្នុងបន្ទុកដែលមានអាយុក្រោម១៨ឆ្នាំទៅតាមដោយរដ្ឋជួយឧបត្ថម្ភរ៉ាប់រងសំបុត្រយន្តហោះថ្នាក់ជំនួញ(Business Class)សម្រាប់ពេលធ្វើដំណើរទៅកាន់តំណែងដំបូងនៅបរទេសនិងសំបុត្រយន្តហោះថ្នាក់ធម្មតា(Economy Class)ពេលចប់អាណត្តិវិលត្រឡប់មកប្រទេសវិញ។

មន្ត្រីនិងបុគ្គលិកថ្នាក់ផ្សេងទៀតដូចមានក្នុងមាត្រា៥នៃអនុក្រឹត្យនេះត្រូវទទួលបានការរ៉ាប់រងសំបុត្រយន្តហោះថ្នាក់ធម្មតា(Economy Class)ពីរដ្ឋដើម្បីធ្វើដំណើរទៅកាន់តំណែងដំបូងនៅបរទេសនិងវិលត្រឡប់មកប្រទេសវិញពេលចប់អាណត្តិ។

**មាត្រា៩ ..**

ឯកអគ្គរាជទូត ត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់រ៉ាប់រងថ្លៃដឹកឥវ៉ាន់ដែលលើសទម្ងន់ចំនួនសរុបមិនលើសពី ៧០(ចិតសិប)គីឡូក្រាមសម្រាប់ការធ្វើដំណើរដូចមានចែងក្នុងមាត្រា៨ខាងលើនេះ។

មន្ត្រីនិងបុគ្គលិកថ្នាក់ផ្សេងទៀត ត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់រ៉ាប់រងថ្លៃដឹកឥវ៉ាន់ដែលលើសទម្ងន់ចំនួនសរុបមិនលើសពី៥០(ហាសិប)គីឡូក្រាមសម្រាប់ការធ្វើដំណើរដូចមានចែងក្នុងមាត្រា៨ខាងលើនេះ។

**មាត្រា១០ ..**

ការកែប្រែចំណាត់ថ្នាក់ប្រទេស ការបង្កើត ការលុប និងការកែសម្រួលមុខតំណែងមន្ត្រីនិងបុគ្គលិកនៅតាមស្ថានតំណាងកម្ពុជានៅបរទេស ព្រមទាំងការកែសម្រួលបៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន និងការឧបត្ថម្ភផ្សេងៗ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៣
## ការគ្រប់គ្រងមន្ត្រីនិងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស

**មាត្រា១១ .-**

ការពិពណ៌នាមុខតំណែងមន្ត្រី និង បុគ្គលិកទាំងអស់ដែលបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេសត្រូវកំណត់ដោយប្រកាសដោយឡែករបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា១២ .-**

មុខតំណែងដែលត្រូវបានតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យរួមមាន៖

- ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព
- អនុប្រធានស្ថានតំណាងអចិន្ត្រៃយ៍(ឋានៈជាអគ្គរាជទូត)។

មុខតំណែងដែលត្រូវបានតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយអនុក្រឹត្យ រួមមាន៖

- ភារធារីពេញសមត្ថភាព
- អគ្គទីប្រឹក្សាស្ថានទូតឬស្ថានតំណាងអចិន្ត្រៃយ៍
- ទីប្រឹក្សាស្ថានទូតឬស្ថានតំណាងអចិន្ត្រៃយ៍
- ទីប្រឹក្សាយោធា
- ទីប្រឹក្សានគរបាលជាតិ
- ទីប្រឹក្សាបច្ចេកទេស(សេដ្ឋកិច្ច ពាណិជ្ជកម្ម អប់រំ វប្បធម៌ និងការងារពលករ)
- អគ្គកុងស៊ុល។

ក្រៅពីមុខតំណែងខាងលើ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីនិងបុគ្គលិកដែលមានចែងក្នុងមាត្រា៥នៃអនុក្រឹត្យនេះ ត្រូវសម្រេចដោយប្រកាសរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីនិងបុគ្គលិកពីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវសម្រេចឬលើកសំណើដោយរដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិជូននាយករដ្ឋមន្ត្រី។

ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីនិងបុគ្គលិកពីក្រសួង ស្ថាប័នផ្សេង ត្រូវផ្អែកលើសំណើរបស់ប្រធានស្ថាប័នពាក់ព័ន្ធមកក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីចេញប្រកាសឬលើកសំណើជូននាយករដ្ឋមន្ត្រី។

មន្ត្រីនិងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស មានអាណត្តិ៣(បី)ឆ្នាំ។

## ជំពូកទី៤
## វិធាននៃការបើកផ្តល់បៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន និងការឧបត្ថម្ភផ្សេងៗ

**មាត្រា១៣ .-**

ការបើកផ្តល់បៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន និងការឧបត្ថម្ភផ្សេងៗដែលមានចែងក្នុងមាត្រា៥ មាត្រា៦ និងមាត្រា៧នៃអនុក្រឹត្យនេះ ត្រូវអនុវត្តដោយធ្វើការផ្ទេរតាមធនាគារជាតិនៃកម្ពុជា នៅរៀងរាល់ត្រីមាសនីមួយៗ។

**មាត្រា១៤ .-**

ថវិកាសម្រាប់បៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន និងការឧបត្ថម្ភផ្សេងៗ របស់មន្ត្រីនិងបុគ្គលិកបំពេញភារកិច្ចនៅបរទេស ត្រូវគ្រោងក្នុងកញ្ចប់ថវិការបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា១៥ .-**

ឯកអគ្គរាជទូត អគ្គកុងស៊ុល ឬប្រធានស្ថានតំណាងអចិន្ត្រៃយ៍ ត្រូវទទួលបៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ និងប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូនចាប់តាំងពីថ្ងៃដែលទទួលបានការយល់ព្រម(Agrément)ពីរដ្ឋាភិបាលម្ចាស់ផ្ទះ ដោយថតចម្លងនូវលិខិតឆ្លងដែន សំបុត្រយន្តហោះ កិច្ចសន្យាជួលផ្ទះ សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រកំណើតបញ្ជូនមកក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

មន្ត្រីនិងបុគ្គលិកថ្នាក់ផ្សេងទៀតនៅស្ថានតំណាង នឹងទទួលបានបៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ និងប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន ក្រោយរយៈពេល១(មួយ)ខែនៃកាលបរិច្ឆេទតែងតាំងជាផ្លូវការនិងត្រូវថតចម្លងនូវលិខិតឆ្លងដែន សំបុត្រយន្តហោះ កិច្ចសន្យាជួលផ្ទះ សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រកំណើតបញ្ជូនមកក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

មន្ត្រីនិងបុគ្គលិកដែលត្រូវបានតែងតាំងឱ្យទៅបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស ត្រូវទទួលបៀវត្សនិងការឧបត្ថម្ភផ្សេងៗអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះនិងមិនត្រូវទទួលបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ ព្រមទាំងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីសាធារណៈនៅក្នុងប្រទេសឡើយ។

**មាត្រា១៦ .-**

មន្ត្រីនិងបុគ្គលិកដែលបញ្ចប់ភារកិច្ចពីស្ថានតំណាងកម្ពុជានៅបរទេសត្រូវទទួលបៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន និងការឧបត្ថម្ភផ្សេងៗ ១(មួយ)ខែ បន្ទាប់ពីថ្ងៃបញ្ចប់អាណត្តិបេសកកម្មអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ដើម្បីរៀបចំឯកសារនិងផ្ទេរការងារផ្សេងៗនិងត្រូវមកបង្ហាញខ្លួននៅអង្គភាពដើមយ៉ាងយូរក្នុងសប្តាហ៍ទី២ ក្រោយពីការបញ្ចប់ភារកិច្ចវិលចូលប្រទេសវិញ។

មន្ត្រីនិងបុគ្គលិកដែលបញ្ចប់ភារកិច្ចពីស្ថានតំណាងកម្ពុជានៅបរទេស ត្រូវទទួលបានការរៀបចំផ្តល់បៀវត្សមូលដ្ឋានស្របតាមក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់សាមីខ្លួន ព្រមទាំងប្រាក់បំណាច់មុខងារផ្អែកលើមុខតំណែងក្នុងមុខងារសាធារណៈដែលមានមុនពេលតែងតាំងឱ្យទៅបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេសនិងប្រាក់បន្ទាប់បន្សំផ្សេងទៀតអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មន្ត្រីនិងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេសត្រូវបានដំឡើងថ្នាក់និង/ឬឋានន្តរស័ក្តិដោយស្វ័យប្រវត្តិ នៅថ្ងៃទី១៣ ខែមេសានៃឆ្នាំនីមួយៗផ្អែកលើអតីតភាពការងារ ២(ពីរ)ឆ្នាំ។

មន្ត្រីនិងបុគ្គលិកនឹងទទួលបានសិទ្ធិអាទិភាពក្នុងការតែងតាំងក្នុងមុខតំណែងទំនេរសមស្របផ្អែកលើរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ននិងការសម្រេចរបស់ប្រធានស្ថាប័ន។

**មាត្រា១៧ .-**

បៀវត្សប្រចាំខែ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូន និងការឧបត្ថម្ភផ្សេងៗដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ តទៅ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១៨ ..**

អនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ស្តីពីប្រាក់បំណាច់និងប្រាក់ឧបត្ថម្ភផ្សេងៗសំរាប់មន្ត្រីរាជការបំពេញភារកិច្ចនៅក្រៅប្រទេស និង អនុក្រឹត្យលេខ៤៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០២ ស្តីពីការដំឡើងប្រព័ន្ធហិរញ្ញកិច្ចសម្រាប់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សាធារណរដ្ឋគុយបា និងស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំក្រុងហូជីមិញនិងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**

**ប្រាក់ សុខុន**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ